The speech of Hun Sen in closing national sports for Cambodian handicap.

# សុន្ទរកថា

**សម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី ២**

**នៃរាជរដ្ឋាភិបាលកម្ពុជា បិទទិវាកីឡាជាតិ ជនពិការកម្ពុជា**

*(ពហុកីឡាដ្ឋានជាតិ អូឡាំពិក ថ្ងៃ ព្រហស្បតិ៍ ទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៨)*

- *ឯកឧត្ដម អ្នកឧកញ៉ា លោកជំទាវ អគ្គទូត អស់លោក លោកស្រី និងនាងកញ្ញាទាំងអស់*
- *កីឡាករ កីឡាការិនីទាំងអស់*

នេះជាលើកទី ៥ ហើយដែលយើងបានប្រារព្ធទិវាកីឡាជាតិ ជនពិការកម្ពុជា ។ រាល់លើកដែលយើងបានប្រារព្ធទិវាជាតិនេះ យើងតែងតែបំផុសបាននូវចលនាដ៏កុះករថែមទៀតដើម្បីលើកទឹកចិត្តដល់សង្គមយើង ក្នុងលុបបំបាត់នូវភាពពិការពីផ្លូវចិត្ត តាមរយៈការបង្ហាញនូវលទ្ធភាព សមត្ថភាពរបស់បងប្អូនជនពិការយើង ។

ដូចឯកឧត្ដម ស៊ុយ សែម រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ដែលបានថ្លែងក្នុងពេលបើក



ទិវាកាលពីម្សិលម៉ិញនេះ បានបញ្ជាក់ហើយថា ទោះបីយើងជាប់ដៃមមាញឹកក្នុងការរៀបចំបោះឆ្នោតយ៉ាងណាក៏ដោយ ក៏យើងនៅតែប្រារព្ធមិនអោយខកខាន នូវទិវាកីឡាជាតិនេះរបស់បងប្អូនជនពិការ ។ ជាការពិត យើងមិនអាចបំភ្លេចបាននូវជនពិការណាម្នាក់របស់យើងបានឡើយ ។ ឥឡូវនេះដោយមានការលើកទឹកចិត្តពីសង្គម ជនពិការរបស់យើងកំពុងតែបណ្ដុះឡើងវិញនូវសមត្ថភាពរបស់ខ្លួន ហើយដូចឯកឧត្ដមឯកអគ្គរដ្ឋទូតអូស្ត្រាលី បានថ្លែងអំបាញ់ម៉ិញហើយថា «*ជោគជ័យរបស់កីឡាករអាជីពលើឆាកអន្តរជាតិ រួមទាំងអត្តពលករពិការផង បាននឹងកំពុងត្រូវលើកស្ទួយមោទនភាពជាតិ និងកិត្យានុភាពអន្តរជាតិផង* » ។ ម៉្យាងវិញទៀតការប្រកួតកីឡាអូឡាំពិកឆ្នាំ ២០០០ ខាងមុខនេះ ក៏តម្រូវអោយការប្រកួតកីឡាអូឡាំពិកផ្នែកជនពិការហៅថា ប៉ារ៉ាឡាំពិក ត្រូវតែមានលក្ខណៈនិងស្ដង់ដាដូចខ្លួនដែរ ។ ប្រការនេះបានលុបបំបាត់នូវការខុសគ្នារវាងជនពិការ និងមិនពិការក្នុងក្របខ័ណ្ឌកីឡារួចទៅហើយ ។ អ្វីដែលខ្ញុំចង់និយាយនៅពេលនេះ គឺអត្ថន័យដ៏ធំធេង នៃការរៀបចំទិវាកីឡាជាតិជនពិការរបស់យើងឆ្ពោះទៅរក

ការប្រកួតលើកដំបូងរបស់ខ្លួននៅលើឆាកអន្តរជាតិ ដែលមានស្តង់ដាដូចអូឡាំពិក នាទីក្រុងស៊ីដនី ឆ្នាំ ២០០០ ។ ខ្ញុំក៏ជាជនពិការម្នាក់ ខ្ញុំមានសង្ឃឹមថា ជនពិការយើង នឹងទទួលបានជោគជ័យ ។

វិស័យកីឡាកម្ពុជា ក្នុងសម័យសង្គមរាស្ត្រនិយម ដែលមានព្រះករុណាជាអម្ចាស់ សម្តេចព្រះ នរោត្តម សីហនុ ដឹកនាំ ធ្លាប់ទទួលបាននូវភាពរុងរឿង ហើយមានកីឡាករជាច្រើនបានទទួលមេដាយមាស មេដាយប្រាក់ និងមេដាយសំរឹទ្ធ ។ ឥឡូវក្នុងសម័យរាជាណាចក្រទី ២ នេះ ពិតមែនតែកីឡាករយើងមិនទាន់ដណ្តើមបានស្នាដៃដូចពេលមុន តែខ្ញុំសង្ឃឹមថា អាចមានបងប្អូនពិការយើង ទទួលបានស្នាដៃឆ្នើមក្នុងការប្រកួតប៉ារ៉ាឡាំពិក ឆ្នាំ ២០០០ នៅទីក្រុងស៊ីដនី ជាមិនខាន ។ ដោយសេចក្តីសង្ឃឹមនេះហើយដែលក្នុងនាមរាជរដ្ឋាភិបាល ក្នុងនាមឯកឧត្តម អ៊ឹង ហួត នាយករដ្ឋមន្ត្រីទី ១ និងក្នុងនាមខ្ញុំផ្ទាល់ព្រមទាំងភរិយា សូមថ្លែងអំណរគុណចំពោះស្ថានទូតអូស្ត្រាលីប្រចាំនៅកម្ពុជា ដែលបានជួយអត្តពលករពិការកម្ពុជា ជាពិសេសជួយដល់ការបង្កើតនូវគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិក



កម្ពុជា ដែលមានរូបខ្ញុំជាប្រធាន ហើយដែលថ្ងៃនេះយើងបានបង្ហាញនូវរូបសញ្ញាជាផ្លូវការនៃប៉ារ៉ាឡាំពិកកម្ពុជាក្នុងទិវារបស់យើងនេះ ។

*បងប្អូនជនពិការទាំងអស់ជាទីស្រឡាញ់ !*

អ្នកដែលផ្តល់តម្លៃដល់អ្នកពិការមុនដំបូងបង្អស់គឺខ្លួនយើងជាអ្នកពិការម្នាក់ៗនេះឯង ហើយសង្គមយើងទាំងមូលនឹងជួយលើកទឹកចិត្តដល់យើង និងលើកស្ទួយដល់យើង ។ ឥឡូវនេះជនពិការកំពុងបង្ហាញថា «ខ្លួនមិនត្រឹមតែមានលទ្ធភាពផ្តល់ស្នាដៃដល់សង្គមយើងប៉ុណ្ណោះទេ ថែមទាំងអាចជួយផ្តល់កិត្យានុភាពដល់ប្រទេសជាតិ និងរួមចំណែកផ្តល់កិត្យានុភាពដល់ឆាកអន្តរជាតិទៀតផង »។ ពាក្យមួយឃ្លាដែលយើងអាចដណ្តើមបាននៅពេលនេះ បានធ្វើអោយខ្ញុំធូស្បើយពីការនឿយហត់ដ៏ខ្លាំងរបស់ខ្ញុំ ក្នុងប៉ុន្មានឆ្នាំមកហើយក្នុងចលនារំដោះភាពពិការផ្លូវចិត្តពីក្នុងសង្គមយើង ហើយធ្វើអោយខ្ញុំកាន់តែមានកម្លាំងថែមទៀតក្នុងឆាកនយោបាយ សង្គម សេដ្ឋកិច្ច និងការបំរើដល់ជីវភាព វឌ្ឍនៈភាពរបស់ប្រជាពលរដ្ឋយើងទាំងអស់ ។

មុននឹងប្រកាសបិទពិធីប្រកួតកីឡាលើកទី ៥ នៃទិវាជាតិរបស់យើងនាពេលនេះ មុននឹងប្រគល់ជូននូវពានរង្វាន់ ហើយមុននឹងជំរាបលាបងប្អូនកីឡាករ កីឡាការិនីដែលបានចូលរួមប្រកួតក្នុងឆន្ទៈលែងពិការទៀតហើយនោះ ខ្ញុំសូមផ្តាំផ្ញើដល់បងប្អូនពិការទាំងអស់ទូទាំងប្រទេសថា សូមកុំភ្លេចទៅចុះឈ្មោះបោះឆ្នោត និងសូមកុំភ្លេចទៅបោះឆ្នោត ដើម្បីបង្ហាញថា យើងមិនពិការទៀតទេ ហើយសូមអោយកីឡាករយើងដណ្តើមបានស្នាដៃឆ្នើមក្នុងការប្រកួតប៉ារ៉ាឡាំពិក ឆ្នាំ ២០០០ នៅទីក្រុងស៊ីដនី ។

ខ្លួនខ្ញុំផ្ទាល់ដែលជាអ្នកពិការម្នាក់ដែរនោះ ខ្ញុំក៏សង្ឃឹមថា នឹងបានឈ្នះឆ្នោត ហើយអ្វីដែលជាការឈ្នះឆ្នោតរបស់ខ្ញុំនោះគឺ ការបោះឆ្នោតមួយគ្មានហឹង្សារាប់ទាំងហឹង្សាពាក្យសំដី ជាការបោះឆ្នោតដែលសេរី យុត្តិធម៌ ត្រឹមត្រូវ និងដែលប្រជាជនកម្ពុជាទទួលយកបានជាមួយក្តីសង្ឃឹមថា នឹងបានអភិវឌ្ឍន៍ប្រទេសជាតិយើងចេញពីភាពក្រីក្រ ។

ភរិយាខ្ញុំ និងខ្ញុំ សូមជូនពរ ជូនឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ អង្គទូត អស់លោក លោកស្រី នាងកញ្ញា និង



កីឡាករ កីឡាការិនីទាំងអស់ សូមទទួលបានជោគជ័យក្នុងឆាកជីវិតរបស់ខ្លួន ។

*សូមអរគុណ !*